ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ០២១ ស ណ ន

# សេចក្តីណែនាំ
## អនុវត្តសាចរាចររបស់រាជរដ្ឋាភិបាល ស្តីពី វិធានការបង្ការទប់ស្កាត់ និង បង្ក្រាបសកម្មភាព “ក្មេងទំនើង”

កន្លងមក ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ខិតខំជំរុញដឹកនាំអង្គភាពក្រោមឱវាទ និងរដ្ឋបាលរាជធានី ខេត្ត រួមសហការជិតស្និទជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីបំផុសចលនាអប់រំប្រជាពលរដ្ឋនៅតាមសហគមន៍ តាមគ្រឹះស្ថានសិក្សា និងអាណាព្យាបាល សិស្សានុសិស្ស ដើម្បីអប់រំបណ្តុះបណ្តាល សីលធម៌ វប្បធម៌ ប្រពៃណីផូផង់របស់ជាតិ លើកកំពស់ការយល់ដឹងសុជីវធម៌ និងផ្តត់គំនិតស្លូតបូត សុភាពរាបសារ ក្នុងស្រទាប់យុវជន ព្រមទាំងចាត់វិធានការ បង្ការទប់ស្កាត់ និងបង្ក្រាបដាច់ខាតសកម្មភាពរបស់ក្រុម “ ក្មេងទំនើង ” មិនទុកអោយរីករាលដាលបង្កើតឡើងនូវ ក្រុមជនសង្គមងងឹត នៅក្នុងសង្គមជាតិឡើយ ។

ផ្អែកតាមស្មារតី នៃសារាចរលេខ០៤ ស.រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបទប់ស្កាត់សកម្មភាពក្មេងទំនើង ក្រសួងមហាផ្ទៃ សូមកំណត់សមាសភាព “ក្មេងទំនើង” ដូចតទៅ :

ក្មេងទំនើង គឺជាក្មេងល្មើស ដែលធ្វើសកម្មភាពដែលបង្កអោយបាត់សណ្តាប់ធ្នាប់សាធារណៈ និងមានពេលខ្លះបានធ្វើសកម្មភាពឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពល្មើសផ្សេងៗទៀត ប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ធ្វើអោយមានការភ័យខ្លាចដល់ប្រជាពលរដ្ឋ ។

ដើម្បីសារាចរលេខ០៤ ស.រ ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព “ ក្មេងទំនើង ” អោយមានប្រសិទ្ធិភាព ធានាដល់ការគ្រប់គ្រង សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមអោយមានភាពល្អប្រសើរ ក្រសួងមហាផ្ទៃ សូមដាក់ចេញនូវវិធានការដូចខាងក្រោម:

១- គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវធ្វើសម្រង់ស្ថិតិ តម្លើងបញ្ជីមាតិកាដើម្បីក្តាប់បានពីសមាសភាពក្មេងទំនើងទាំងនេះ ទៅតាមប្រភេទនីមួយៗ ដោយមាននគរបាលគ្រប់លំដាប់ថ្នាក់ជាសេនាធិការ ក្នុងទិសដៅធ្វើការគ្រប់គ្រងផង និងបង្ការទប់ស្កាត់ជាមុនផង តាមវិធានការអប់រំ វិធានការរដ្ឋបាល ឬវិធានការច្បាប់ ដើម្បីកាត់បន្ថយសកម្មភាព និងឈានទៅលុបបំបាត់ ក្រុមក្មេងទំនើងល្មើសទាំងនេះ នៅតាមភូមិសាស្ត្រដែលកំពុងគ្រប់គ្រង ។

២- អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវចាត់តាំងនាយកដ្ឋានជំនាញ ដើម្បីរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ណែនាំអំពីជំនាញ វិធានគ្រប់គ្រង និងត្រួតពិនិត្យសមាសភាពក្មេងទំនើងទាំងនោះ អោយបានត្រឹមត្រូវតាមនីតិវិធី ។

៣- រដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបំផុសចលនា ដល់អាណាព្យាបាលរបស់ក្មេងទំនើងទាំងនោះ ប្រជាពលរដ្ឋតាមសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា ព្រមទាំងលោកគ្រូ អ្នកគ្រូអោយមានកាតព្វកិច្ចចូលរួមជួយអប់រំ បង្ការទប់ស្កាត់ និងរាយការណ៍ពីសកម្មភាពក្រុមក្មេងទំនើង ដែលកំពុងកើតមាននៅតាមមូលដ្ឋាន ឬតាមគ្រឹះស្ថានសិក្សា មកសមត្ថកិច្ចដើម្បីមានវិធានការ តាមសេចក្តីណែនាំនេះ ។

៤- រដ្ឋបាលរាជធានី ខេត្ត ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចចេញអាជ្ញាប័ណ្ណត្រូវធ្វើការផ្សព្វផ្សាយជូនដំណឹងណែនាំ ឬដាក់ចេញនូវវិធាន បញ្ញត្តិ ឬបទបញ្ជាផ្នែករដ្ឋបាលចាំបាច់នានាដល់ម្ចាស់ឬអ្នកគ្រប់គ្រងគោលដៅអាជីវកម្មទាំងអស់ដូចជា ផ្ទះសំណាក់ ផ្ទះជួល សណ្ឋាគារ ក្លិបកំសាន្ត រង្គសាលភោជនីយដ្ឋាន។ល។ អោយមានកាតព្វកិច្ចចូលរួមក្នុងការបង្ការ ហាមឃាត់ មិនអោយក្រុមក្មេងទំនើងទាំងនោះប្រមូលផ្តុំគ្នាធ្វើសកម្មភាពបាននៅក្នុងទីកន្លែងដែលខ្លួនកំពុងគ្រប់គ្រង ។

៥- ក្នុងករណីមានសកម្មភាពលេចចេញដោយប្រការណាមួយ បង្ករំខាន ការអុកឡុក ឬមានសកម្មភាព បង្កភាព បាត់សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ពីក្រុមក្មេងទំនើង ភ្នាក់ងារមានសមត្ថកិច្ចនៅមូលដ្ឋាន ត្រូវអន្តរាគមន៍បញ្ឈប់សកម្មភាពទាំងនោះជាបន្ទាន់ និងនាំខ្លួនក្រុមក្មេងទំនើងបង្កទាំងនោះ មកប៉ុស្តិ៍នគរបាលរដ្ឋបាលដែលនៅជិតបំផុតដើម្បីធ្វើកំណត់ហេតុសាកសួរ ដោយមានសាក្សីបញ្ជាក់បំភ្លឺ ព្រមទាំងចាប់យកឧបករណ៍សម្ភារៈ ភស្តុតាង ឬមធ្យោបាយ ធ្វើសកម្មភាពឃាត់ទុកជាបណ្តោះអាសន្ន រួចរាយការណ៍ទៅថ្នាក់លើដើម្បីមានវិធានការចំពោះក្មេងទំនើងល្មើសទាំងនោះ។ ប្រសិនបើការប្រព្រឹត្តសកម្មភាពមានលក្ខណៈអាចអប់រំបាន ពុំមានពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌត្រូវអោយសាម៉ីខ្លួនធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាព ដោយអញ្ជើញអាណាព្យាបាល អោយមកទទួលខុសត្រូវយកទៅអប់រំបន្ថែម ។

៦- ករណីក្មេងទំនើង ទាំងអស់នោះនូវតែបន្តប្រព្រឹត្តសកម្មភាព ច្រើនលើកមិនរាងចាលដែលមន្ត្រី នគរបាលយុត្តិធម៌ពិនិត្យឃើញថា ពុំអាចធ្វើការអប់រំបាន ត្រូវកសាងសំណុំរឿងបញ្ជូនទៅអយ្យការសាលាដំបូងរាជធានី ខេត្ត ដើម្បីមានវិធានការបន្ត ។

-ករណីក្មេងទំនើង បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តតាមនីតិវិធីព្រហ្មទណ្ឌ ធ្វើការឃាត់ខ្លួន កសាងសំណុំរឿងបញ្ជូនទៅអយ្យការ ដើម្បីចាត់វិធានការជាសមត្ថកិច្ចតាមនីតិវិធីនៃច្បាប់។

ទទួលបានសេចក្តីណែនាំនេះ អគ្គស្នងការដ្ឋាននគរបាលជាតិ រដ្ឋបាលរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ ត្រូវរៀបចំផែនការសកម្មភាព ចាត់វិធានការអនុវត្តជាក់ស្តែងអោយមានប្រសិទ្ធិភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**<u>កន្លែងទទួល:</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី

-គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ

-អគ្គស្នងការដ្ឋាននគរបាលជាតិ

-អគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន

-សាលាខេត្ត-រាជធានី

-ឯកសារ កាលប្បវត្តិ